**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:....៤៩......អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតដែនជម្រកសត្វព្រៃ«សង្ឃរុក្ខាវ័ន»**

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១** ._

ត្រូវបានបង្កើតដែនជម្រកសត្វព្រៃ«សង្ឃរុក្ខាវ័ន» ដែលមានផ្ទៃដីសរុបចំនួន ៣០.២៥៤ (បីម៉ឺន សូន្យពាន់ពីររយហាសិបបួន) ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកអន្លង់វែង ស្រុកចុងកាល និងក្រុងសំរោង ខេត្តឧត្តរមានជ័យ ដូចមានផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកាគោល (Datum: WGS1984) ដូចខាងក្រោម៖

| និយាមកាគោល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ID | X | Y | ID | X | Y | ID | X | Y |
| 1 | 351569 | 1570310 | 14 | 364328 | 1565140 | 27 | 364593 | 1560310 |
| 2 | 358593 | 1570310 | 15 | 366537 | 1566630 | 28 | 359448 | 1560310 |
| 3 | 358586 | 1569120 | 16 | 366028 | 1568790 | 29 | 359448 | 1557400 |
| 4 | 361927 | 1569500 | 17 | 364661 | 1567720 | 30 | 358006 | 1557210 |
| 5 | 361021 | 1571090 | 18 | 364640 | 1569990 | 31 | 358063 | 1559980 |
| 6 | 361256 | 1574120 | 19 | 367003 | 1569620 | 32 | 356593 | 1560130 |
| 7 | 362977 | 1574010 | 20 | 366740 | 1573080 | 33 | 356593 | 1563760 |
| 8 | 362944 | 1572120 | 21 | 367268 | 1574240 | 34 | 358015 | 1563540 |
| 9 | 362143 | 1571320 | 22 | 377309 | 1573450 | 35 | 358225 | 1566110 |
| 10 | 363545 | 1567900 | 23 | 377560 | 1558950 | 36 | 355110 | 1566060 |
| 11 | 362396 | 1568310 | 24 | 367954 | 1557490 | 37 | 354969 | 1564540 |
| 12 | 362395 | 1566290 | 25 | 366695 | 1559930 | 38 | 351607 | 1564540 |
| 13 | 364649 | 1566290 | 26 | 364589 | 1558130 | | | |

**មាត្រា២** ._

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ដើម្បីធានាឱ្យមានការថែទាំទីជម្រកសត្វព្រៃ និងប្រព័ន្ធអេកូឡូស៊ី សារព័ន្ធមជ្ឈដ្ឋានធម្មជាតិ ព្រមទាំងធានាឱ្យមានការបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វព្រៃ រុក្ខជាតិ និងជីវៈចម្រុះ
- រក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិ សម្រាប់ការប្រើប្រាស់ដោយនិរន្តរភាព
- លើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាអ្នកពាក់ព័ន្ធក្នុងការថែរក្សា ការពារអភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព។

**មាត្រា៣** ._

ផ្ទៃដីនៃអនុក្រឹត្យដែនជម្រកសត្វព្រៃ «សង្ឃរុក្ខាវ័ន» នេះ មិនរួមបញ្ចូលដីកម្មសិទ្ធិឯកជន និងដីប្រើប្រាស់ជាប្រយោជន៍សាធារណៈ។



www.pheakdeylaw.com

**មាត្រា៤ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃ«សង្ឃរុក្ខាវ័ន» ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តឧត្តរមានជ័យ និងកងកម្លាំងប្រដាប់អាវុធមានសមត្ថកិច្ចដើម្បីជានាកិច្ចគាំពារបរិស្ថាន ការអភិរក្សប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥ រោចខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**អន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

## ផែនទី ដែនជម្រកសត្វព្រៃ «សឡុក្រាច័ន» ស្ថិតក្នុង ខេត្តឧត្ដរមានជ័យ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃ៧ ១២កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី ៥ ខែមេសា ឆ្នាំ២០១៨




**និយាមការគោល**

| ID | X | Y |
|---|---|---|
| 1 | 351569 | 1570310 |
| 2 | 358593 | 1570310 |
| 3 | 358586 | 1569120 |
| 4 | 361927 | 1569500 |
| 5 | 361021 | 1571090 |
| 6 | 361256 | 1574120 |
| 7 | 362977 | 1574010 |
| 8 | 362944 | 1572120 |
| 9 | 362143 | 1571320 |
| 10 | 363545 | 1567900 |
| 11 | 362396 | 1568310 |
| 12 | 362395 | 1566290 |
| 13 | 364649 | 1566290 |
| 14 | 364328 | 1565140 |
| 15 | 366537 | 1566630 |
| 16 | 366028 | 1568790 |
| 17 | 364661 | 1567720 |
| 18 | 364640 | 1569990 |
| 19 | 367003 | 1569620 |
| 20 | 366740 | 1573080 |
| 21 | 367268 | 1574240 |
| 22 | 377309 | 1573450 |
| 23 | 377560 | 1558950 |
| 24 | 367965 | 1557240 |
| 25 | 366319 | 1556710 |
| 26 | [illegible] | [illegible] |
| 27 | 364593 | 1560310 |
| 28 | 359448 | 1560310 |
| 29 | 359448 | 1557400 |
| 30 | 358006 | 1557210 |
| 31 | 358063 | 1559980 |
| 32 | 356593 | 1560130 |
| 33 | 356593 | 1563760 |
| 34 | 358015 | 1563540 |
| 35 | 358225 | 1566110 |
| 36 | 355110 | 1566060 |
| 37 | 354969 | 1564540 |
| 38 | 351607 | 1564540 |

**សញ្ញាសម្គាល់**

- ចំណុចនិយាមការ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ឃុំ
- ផ្លូវ
- ទឹក
- ព្រំប្រទល់ដែនជម្រកសត្វព្រៃសឡុក្រាច័ន

**គម្របព្រៃឈើឆ្នាំ២០១៤**

- ព្រៃស្រោង
- ព្រៃពាក់កណ្ដាលស្រោង
- ព្រៃល្បោះ
- ព្រៃឫស្សី
- ព្រៃលិចទឹក
- ព្រៃដុះឡើងវិញ
- ដីគ្មានគម្របព្រៃឈើ

## ផ្ទៃដី ដែនជម្រកសត្វព្រៃ «សឡុក្រាច័ន» សរុប ៣០.២៥៤ ហិកតា

ថ្ងៃ ៧ ១២ កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ថ្ងៃ ... ខែ ... ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៨ ធ្វើនៅឧត្ដរមានជ័យ, ថ្ងៃទី ៩ ខែ មេសា ឆ្នាំ២០១៨

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

អភិបាល នៃគណៈអភិបាលខេត្តឧត្ដរមានជ័យ

ស. ចាវី